# ការពង្រឹងភាពជាអ្នកដឹកនាំដល់ប្រជាជន

## គំរូជាឧទាហរណ៍ពីប្រទេសឥណ្ឌា

PRIA ក្នុងកិច្ចសហការជាមួយដៃគូដទៃទៀត បានចាប់ផ្តើមអន្តរាគមន៍ពង្រឹង ភាពជាអ្នកដឹកនាំតាមបែបប្រជាជន ដោយមានការរំពឹងទុកថា អ្នកដែលមានភាពប្រពៃក្នុងការដឹកនាំ និងបណ្តាញរបស់ពួកគេ អាចសម្រួលដល់ទំនាក់ ទំនងរវាងសមាគមបង្កើតដោយប្រជាជន និង ស្ថាប័នគ្រប់គ្រងផ្សេងៗ ដើម្បីពួកគេអាចប្រាប់ពីតម្រូវការ និង ការទទួលបានសិទ្ធិអំណាចរបស់ខ្លួន ។ កម្មវិធីនេះ ទោះបីជាបង្កើតឡើងដំបូងនៅក្នុង ឆ្នាំ ២០០២ ជាអន្តរាគមន៍ដែលមានតែឯកឯងក៏ដោយ ប៉ុន្តែនៅដើមឆ្នាំ ២០០៣ វាបានប្រែក្លាយជាវិធីសាស្ត្រមូលដ្ឋានមួយក្នុងចំណោមគម្រោងយុទ្ធសាស្ត្រ និង កម្មវិធីទាំងឡាយរបស់ PRIA ។ យោងទៅតាមគម្រោងកម្មវិធីរបស់ PRIA ស្តីពី " អភិបាលកិច្ចសម្រាលទុក្ខកង្វល់ប្រជាជន " វាបានពង្រឹងសមូហភាពប្រជាជន និងការដឹកនាំតាមបែបប្រជាជន ហើយត្រូវបានគេមើលឃើញថាជាឧបករណ៍សម្រាប់ពង្រឹងតម្រូវការពីថ្នាក់ក្រោមទៅដល់ថ្នាក់លើសម្រាប់ស្ថាប័នគ្រប់គ្រងក្នុងតំបន់ដែលមានការទទួលខុសត្រូវ (គណនេយ្យភាព) និងតម្លាភាពដែលរួមមានដូចជា ស្ថាប័នដែលមានឈ្មោះថា *ផាចាយ៉ាទីរ៉ាយ* និង ស្ថាប័នផ្សេងៗទៀតក្នុងទីក្រុង ។ PRIA និងដៃគូបានសម្រេចចិត្តពិចារណាថា នឹងមិនបង្កើតស្ថាប័នថ្នាក់មូលដ្ឋានថ្មីឡើយ ។ នៅជំហានដំបូង មានការខិតខំយ៉ាងខ្លាំង ដើម្បីកំណត់យកអង្គការណាដែលមានទីតាំងនៅក្នុងសហគមន៍ស្រាប់ ។ ដូច្នេះហើយ អង្គការស្ត្រីជួយខ្លួនឯង, ម៉ាហីឡា *ម៉ានដាល,* អង្គការយុវជន, គណៈកម្មាធិការនានាដែលផ្តួចផ្តើមគម្រោងផ្សេងៗដូចជាគណៈកម្មាធិការ *វ៉ាធីសេធ,* សមាគមអ្នកប្រើប្រាស់ទឹក, គណៈកម្មាធិការអប់រំភូមិស្រុក, សហគមន៍អភិវឌ្ឍន៍សង្គម (បង្កើតឡើងក្រោមកម្មវិធីជំនួយរបស់រដ្ឋាភិបាលកណ្តាលទៅលើ *ស្វរណា ចាយ៉ាទី សាហេរិ រ៉ូសហ្គា យ៉ូណា*), អង្គការអតីតយុទ្ធជន, និង អង្គការដទៃច្រើនទៀត ទាំងអស់នេះត្រូវបានបណ្តុះបណ្តាល និង ប្រមូលផ្តុំ ។ អ្នកដឹកនាំសហគមន៍បច្ចុប្បន្ន ត្រូវបានគេផ្តល់ការបណ្តុះបណ្តាល និង ផ្តល់ជាទុនតាមរយៈការអប់រំ ឱ្យចេះសហការ និងទំនាក់ទំនងជាមួយស្ថាប័ននៅសហគមន៍នានា ក៏ដូចជាទីភ្នាក់ងាររដ្ឋ និង ស្ថាប័នគ្រប់គ្រងក្នុងតំបន់ជាច្រើន។

ពីរឆ្នាំដំបូងនៃអន្តរាគមន៍នេះ (២០០២-២០០៤) ពិសេស គឺ ដើម្បីលើកទឹកចិត្ត និង កំណត់គោលដៅទៅលើភាពដឹកនាំរបស់ស្ត្រី ។ ជាលទ្ធផល SHGs និងម៉ាហីឡាម៉ានដាល បានចូលរួមមួយភាគធំក្នុងអន្តរាគមន៍

នេះ ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំមុនៗ ភាពដឹកនាំនៃបុរស ពិសេសយុវជនក៏ត្រូវបានកំណត់ជាគោលដៅផងដែរ ប៉ុន្តែអ្វីដែលផ្តោតសំខាន់ គឺតែទៅលើការបង្កើតភាពដឹកនាំនៃស្រ្តី ។

វិធីសាស្រ្តពហុមាត្រិក្នុងការកសាងសមត្ថភាពដល់អ្នកដឹកតាមបែបប្រជាជន និង សមូហភាពត្រូវបានគេប្រើប្រាស់ដើម្បីសម្រេចបានគោលដៅ ។ ខាងក្រោមនេះគឺជាការពិពណ៌នាសង្ខេបនៃវិធីសាស្រ្ត ក្នុងការពង្រឹងសមត្ថភាព ។

(ក) ***ការរៀបចំសំណុំឯកសារសម្រាប់សមូហភាពប្រជាជន :*** ដើម្បីជាលក្ខខណ្ឌមុនទំនាក់ទំនង កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីបង្ហាញផ្លូវដល់អង្គការមហាជន (Communty Based Orgainaztion ) ក្នុងការកំណត់ឱ្យបាននូវអ្នកដឹកនាំប្រជាជនដែលមានសក្តានុភាព ។ បណ្តុំទិន្នន័យ ដ៏ច្រើនត្រូវបាន រៀបចំសម្រាប់មន្ទីរ និង អាជ្ញាធរក្នុងតំបន់ ដែលPRIA និងដៃគូកំពុងបំពេញការងារ ។ គេបានដឹងយ៉ាងឆាប់រហ័សថា មានប្រជាជនជាច្រើនសកម្មក្នុងសហគមន៍ ដោយពួកគេបានចូលរួមក្នុងសកម្មភាពតាមបែបសមូហភាពផ្សេងៗ ឬចេះជួយយកអាសារអ្នកជិតខាងដែលចូលរួមជាមួយគ្នាតាមវិធីផ្សេងៗ ។ សមាជិកក្នុងសហគមន៍បានទទួលស្គាល់ការរួមចំណែករបស់ពួកគេ ។ កិច្ចខឹតខំ ប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីទាក់ទងឱ្យប្រជាជនទាំងនោះបង្កើតកម្មវិធីជុំវិញសមត្ថភាពដែលពួកគេមានស្រាប់ ។

(ខ) ***ការបណ្តុះបណ្តាលសម្រាប់ប្រជាជនសមូហភាព និង ការដឹកនាំប្រជាជន :*** កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លីជាបន្តបន្ទាប់ រយៈពេលខ្លី (ពី ១ ថ្ងៃ ទៅ៣ថ្ងៃ) ស្តីអំពីសមូហភាពប្រជាជន និងការដឹកនាំតាមបែបប្រជាជនត្រូវបានរៀបចំឡើងស្ទើរតែនៅគ្រប់តំបន់ ។ គោលបំណងនៃកម្មវិធីបង្វឹកបង្ហាត់នេះរាប់បញ្ចូលតាំងពីការកសាងទស្សនៈស្តីអំពីអភិបាលកិច្ចថ្នាក់មូលដ្ឋាន និង ភាពជាពលរដ្ឋដើម្បីពង្រឹងជំនាញ អំពីការគ្រប់គ្រងក្រុម, ការធ្វើផែនការកម្រិតមូលដ្ឋាន, ការប្រមូលផ្តុំ *ក្រាម* (Gram Sabha) *សាប់ផានិង* វ៉តសាប់ផា ( Ward Sabha), យុត្តិធម៌យេនឌ័រ ។ល។ នៅកន្លែងជាច្រើន ការបញ្ចាំងខ្សែភាពយន្តត្រូវបានរៀបចំឡើងជាឧបករណ៍សិក្សា ។ គោលបំណងគឺ ដើម្បីចែករំលែកដំណើររឿងនៃការ តស៊ូរបស់ក្រុមដទៃផ្សេងៗ និងដើម្បីផ្តួចផ្តើមការពិភាក្សា ជាសមូហភាព និង សហគមន៍ ។

(គ) ***កិច្ចប្រជុំជាទៀងទាត់ និងការគាំទ្រក្នុងដំណើរការ :*** អន្តរាគមន៍នេះតម្រូវឱ្យមានកិច្ចប្រជុំទៀងទាត់ និងការគាំទ្រក្នុងដំណើរការចំពោះសមូហភាព និង ការដឹកនាំរបស់គេ ។ នៅតំបន់ជាច្រើន ការប្រឹក្សាយោបល់, ការណែនាំ និង ការគាំទ្រដល់បុគ្គលអ្នកដឹកនាំ បានបង្ហាញឱ្យឃើញថាមានសារៈប្រយោជន៍ណាស់ ។ សមាជិកនៃសមូហភាពប្រជាជន ត្រូវបានផ្តល់នូវការគាំទ្រដែលជាទូទៅទាក់ទងនឹងតម្រូវការប្រចាំថ្ងៃ របស់ពួកគេ ។

ដោយសារតែសមូហភាព កំពុងស្ថិតក្នុងដំណាក់កាលក្មេងខ្ចីស្ទើរតែគ្រប់តំបន់ ដូច្នេះសមូហភាព និង ការដឹកនាំតែងតែទាមទារនូវការគាំទ្រយ៉ាងជិតស្និទ្ធ ។

**(ឃ) ទស្សនកិច្ចសិក្សា :** គោលបំណងនៃការរៀបចំទស្សនកិច្ចសិក្សាគឺដើម្បីសម្រួលការសិក្សាដល់អ្នកដឹកនាំប្រជាជនលើ គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ផ្សេងៗដែលពួកគេអាចចម្លងយកបាន ។ ដោយសារមានតែបុគ្គលដែលបានជ្រើសរើសមួយចំនួន ប៉ុណ្ណោះដែលអាចចូលរួមក្នុងទស្សនកិច្ចសិក្សាបាន ដូច្នេះការខំប្រឹងប្រែង ត្រូវបានធ្វើឡើង ដើម្បីឱ្យការសិក្សា ដែលអ្នកដឹកនាំប្រជាជនទទួលបាន អាចចែករំលែកទៅឱ្យសមាជិកផ្សេងទៀតនៃសមូហភាព និងសហគមន៍ជាបន្ទាន់ ។

**(ង) សិក្ខាសាលា/កិច្ចប្រជុំអំពីទំនាក់ទំនងប្រជាជនមូលដ្ឋាន :** លទ្ធផលរំពឹងទុកមួយនៃអន្តរាគមន៍ពង្រឹងសមូហភាពប្រជាជន និង ការដឹកនាំប្រជាពលរដ្ឋ គឺដើម្បីជំរុញឱ្យមានទំនាក់ទំនងដ៏មានប្រសិទ្ធភាពរវាងប្រជាពលរដ្ឋ និងស្ថាប័នគ្រប់គ្រង ។ ក្នុងតំបន់ជាច្រើនកិច្ចប្រជុំទំនាក់ទំនង និងកម្មវិធីអប់រំផ្សេងៗបានបង្កភាពងាយស្រួលក្នុងការផ្តួចផ្តើមការនិយាយទាក់ទងគ្នា ។ គោលបំណងនៃការប្រជុំទំនាក់ទំនងនេះរាប់បញ្ចូល ចាប់ពីការផ្តួចផ្តើមការសន្ទនាទាក់ទងគ្នាលើបញ្ហាអភិវឌ្ឍន៍ជាក់លាក់ ដើម្បីចែកចាយព័ត៌មានក្នុងចំណោមសមូហភាពប្រជាជន ។

**(ច) ការរៀបចំយុទ្ធនាការ :** ចង្កោមនៃយុទ្ធនាការត្រូវបានរៀបចំឡើងទៅលើការយល់ដឹងរបស់អ្នកបោះឆ្នោតមុនពេលបោះឆ្នោត, ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការចុះបញ្ជីកំណើតនិងមរណភាព និង ការគ្រប់គ្រងកាកសំណល់រឹង ។ ប្រព័ន្ធផ្សព្វផ្សាយប្រជាប្រិយដូចជាចម្រៀង, របាំ និងការសម្តែងតាមផ្លូវត្រូវបានប្រើប្រាស់យ៉ាងច្រើនក្នុងយុទ្ធនាការទាំងនេះ ។ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីកសាងភាពជាម្ចាស់ តាមរយៈការធ្វើឱ្យមានជាប់ពាក់ព័ន្ធនឹងសមូហភាពប្រជាជន និង សិទ្ធិអ្នកដឹកនាំចាប់ពីការធ្វើផែនការអនុវត្តយុទ្ធនាការទាំងនេះ ។

**(ឆ) ការសម្រួលបណ្តាញនៃសមូហភាពប្រជាជន :** ការសម្រួល និង ជំរុញបណ្តាញនៃសមូហភាពប្រជាពលរដ្ឋដោយផ្តោតសំខាន់លើស្ត្រី, ដាលីត, និងជនជាតិកុលសម្ព័ន្ធ គឺជាគោលដៅច្បាស់លាស់មួយនៃអន្តរាគមន៍កសាងសង្គមស៊ីវិលនៅកម្រិតថ្នាក់ស្រុក និង កម្រិតទាបជាងនេះ ។ គំនិតផ្តួចផ្តើមបានចាប់ផ្តើមបង្ហាញពីលទ្ធផលដ៏គាប់ចិត្តនៅក្នុងតំបន់ជាច្រើន ប៉ុន្តែក៏បង្ហាញនូវឧបសគ្គដ៏ពិបាក ចំពោះការបន្តពង្រឹង សមូហភាពទាំងនេះផងដែរ ។

## ការជាប់ទាក់ទងគ្នានៃការកសាងសមត្ថភាព

ការបន្តប្រើប្រាស់នៃវិធីសាស្ត្រកសាងសមត្ថភាពពហុមាត្រា និងអន្តរាគមន៍ជាច្រើនបានផ្តល់នូវភាគលាភជួយជំរុញ ឱ្យអ្នកដឹកនាំពលរដ្ឋចូលរួមពាក់ព័ន្ធក្នុងការបង្កើតទំហំនៃសម្ព័ហភាព ព្រមទាំងសកម្មភាពបុគ្គលនៅកម្រិតថ្នាក់សហគមន៍ ។ ពួកគេមិនត្រឹមតែ អនុវត្តកាតព្វកិច្ចនេះដោយស្ម័គ្រចិត្តប៉ុណ្ណោះទេ ថែមទាំងបានដឹកនាំសម្ព័ហភាពក្នុងសកម្មភាពសង្គម និងនយោបាយតាំងពីដំបូងទៀតផង ។ ទោះជាធម្មតាការចូលរួមមានការប្រែប្រួលយ៉ាងណាក៏ដោយ ក៏គេនៅតែអាចឃើញមានបរិបទ និងប្រពលភាព និង ឧបសគ្គរួមគ្នាជាទូទៅដែរ ។

(១) ***ការផ្តើមធ្វើការងារជួយខ្លួនឯង*** **:** អ្នកដឹកនាំពលរដ្ឋខ្លួនឯងបានដឹង ព្រមទាំងញ៉ាំងសហគមន៍ឱ្យបានដឹងថាពួកគេមិនមែនពឹងផ្អែក ទាំងស្រុងទៅលើ តែរដ្ឋាភិបាលក្នុងរាល់សកម្មភាពអភិវឌ្ឍន៍ឡើយ ។ ពួកគេបានក្លាយទៅជាឧបករណ៍ក្នុងការប្រមូលផ្តុំប្រជាពលរដ្ឋឱ្យអនុវត្តសកម្មភាពដូចជាការកែលម្អអាគារសិក្សា, ការរួមកម្លាំងកសាងផ្លូវថ្នល់, ការសម្អាតស្រះទឹក ។ល។ នៅក្នុងតំបន់ជាច្រើន ប្រជាពលរដ្ឋបានចេញសកម្មភាពមុនក្នុងការផ្តើមគំនិតអភិវឌ្ឍន៍ ហើយបន្ទាប់មកអាជ្ញាធររដ្ឋក៏បានផ្តល់ការគាំទ្រជាខាងក្រោយ ។

(២) ***ការចូលរួមក្នុងការធ្វើផែនការពីក្រោមទៅលើនៅកម្រិតថ្នាក់មូលដ្ឋាន*** **:** ទោះបីជាក្នុងវោហារសាស្ត្រនិយាយអំពីដំណើរការធ្វើផែនការ ដោយមានការចូលរួមពីក្រោមឡើងលើអស់រយៈកាលជាច្រើនទសវត្សរ៍កន្លងមកហើយក្តី ក៏ប្រព័ន្ធធ្វើផែនការឥណ្ឌានៅតែធ្វើពីលើចុះក្រោម យ៉ាងច្រើននៅឡើយ ។ ច្បាប់វិសោធនកម្មធម្មនុញ្ញលើកទី ៧៣ និង ៧៤ បង្កើតឱ្យមានឱកាសដល់ស្ថាប័ន អភិបាលកិច្ចថ្នាក់មូលដ្ឋានដែលត្រូវបានគេបោះឆ្នោតជ្រើសរើស ដូចជា *បញ្ចាយ័ត្យ* និង អាជ្ញាធរក្នុងតំបន់ឱ្យផ្តួចផ្តើមដំណើរការធ្វើផែនការពីក្រោមឡើងលើ ។ យ៉ាងណាមិញ ការបដិសេធធនធាន និង សមត្ថភាពនៃស្ថាប័នទាំងនេះពីស្ថាប័នគ្រប់គ្រងថ្នាក់លើ បានបង្កើតឱ្យមានការប្រើប្រាស់ប្រពៃណីចាស់ និង ការទំនាក់ទំនងអំណាច ។ ដោយមិនគាំទ្រនឹងការបដិសេធទាំងនេះ ក្នុងតំបន់មួយចំនួន អ្នកដឹកនាំពលរដ្ឋបានត្រៀមខ្លួនប្រមូលប្រជាពលរដ្ឋដែលគាំទ្រ ដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍ថ្នាក់តំបន់ក្នុងកម្រិត វ៉ត និង ក្រាម បញ្ចាយ័ត្យ ក្នុងកិច្ចសហប្រតិបត្តិការជាមួយ បញ្ចាយ័ត្យ ឬ អាជ្ញាធរក្នុងតំបន់ ។ គេបានរៀបចំការប្រឹក្សាដ៏ទូលំទូលាយនៅក្នុងថ្នាក់ភូមិ និង *មោហល្ល:* ជាមួយក្រុមប្រជាពលរដ្ឋដទៃទៀត និងកំណត់ពីអាទិភាពនៃការអភិវឌ្ឍន៍របស់ប្រជាពលរដ្ឋ ។ ផែនការ លម្អិតត្រូវបានរៀបចំឡើង និង ចែករំលែកជាមួយនឹងស្ថាប័នគ្រប់គ្រងក្នុងតំបន់ ដើម្បីរួមបញ្ចូលអាទិភាព អភិវឌ្ឍន៍ទៅក្នុងផែនការប្រចាំឆ្នាំ ។ ក្នុងតំបន់មួយចំនួន អ្នកដឹកនាំពលរដ្ឋជាច្រើនមិនត្រឹមតែបានបញ្ជាក់ ឱ្យដឹងថាអាទិភាពអភិវឌ្ឍន៍នេះត្រូវបានរួមបញ្ចូល ក្នុងគម្រោងផែនការ បញ្ចាយ័ត្យ និងអាជ្ញាធរតំបន់ ប៉ុណ្ណោះទេ ថែមទាំងបានរួមចំណែក

យ៉ាងសកម្មជាមួយនឹងស្ថាប័នទាំងនេះរហូតដល់ការងារជាក់ស្តែង ត្រូវបានចាប់ផ្តើមឬបញ្ចប់ ។ កិច្ចខិតខំព្យាយាមរបស់អ្នកដឹកនាំពលរដ្ឋ បានផ្តល់ប្រយោជន៍ទៅឱ្យសហគមន៍ ហើយបទពិសោធន៍ក្នុងការរួមចំណែកទាំងអស់នេះបានបង្កើតនូវជំនឿចិត្តជាច្រើន ដល់ពួកគេក្នុងការរៀបចំការរួមចំណែក ថែមទៀតនាពេលអនាគត ។

(២) ***ការប្រមូលផ្តុំ ក្រាម សាប់ផា និង វៃតសាប់ផា :*** ថ្វីបើបញ្ញត្តិធម្មនុញ្ញតម្រូវឱ្យ ក្រាម សាប់ផា ស្ថិតនៅក្នុងកម្រិត ក្រាម បញ្ចយ័ត្ន ក៏ដោយ ភាគច្រើនចង់ឱ្យប្រមូលផ្តុំពួកវាជាបញ្ញត្តិៗ ។ មូលហេតុមួយចំនួនប៉ះពាល់យ៉ាងអាក្រក់ទៅលើប្រសិទ្ធភាពនៃក្រាមសាប់ផា ដែលបានពិភាក្សាលម្អិតរួចទៅហើយ ។ បញ្ហាចំបង ក្នុងចំណោមនោះមានកង្វះខាតព័ត៌មាន និង ភាពព្រងើយកន្តើយ ពីតំណាងរាស្ត្រជាប់ឆ្នោតក៏ដូចជាពីសំណាក់ប្រជាពលរដ្ឋផងដែរ ។ អ្នកដឹកនាំពលរដ្ឋជាច្រើន បន្ទាប់ពីបំពាក់ខ្លួនគេនូវព័ត៌មានទាក់ទិន និង មានការយល់ដឹងហើយ បានសំដែងជាភ្នាក់ងារកែប្រែដោយចែកចាយព័ត៌មានដែលទាក់ទងនឹងការប្រជុំ ក្រាមសាប់ផា ទីកន្លែងប្រជុំ ។ល។ ទៅឱ្យសមាជិក ក្រាម សាប់ផា ដទៃទៀត ។ ពួកគេបញ្ជាក់ច្បាស់ពីបញ្ហាអភិវឌ្ឍន៍ផ្សេងទៀតក្នុងក្រាមសាប់ផា ហើយព្យាយាមកែលម្អនូវការប្រព្រឹត្តិរបស់ក្រាមសាប់ផា ។ ពួកគេជាច្រើនបានទទួលជោគជ័យ ក្នុងការ ធ្វើឱ្យអាជ្ញាធរថ្នាក់ភូមិឃុំ ប្រកាសពីកាលបរិច្ឆេទ និង ទីកន្លែងជាមុន ដើម្បីឱ្យពួកគេអាចបន្តប្រាប់ព័ត៌មាននេះទៅប្រជាជនដទៃ ។ ប្រជាជននៅជាយក្រុងនៃក្រុងតូច និង មធ្យមនៃប្រទេសឥណ្ឌា នៅតែត្រូវដកហូតសិទ្ធិដោយវិសោធនកម្មធម្មនុញ្ញនៃយន្តការ ស្របស្រដៀងគ្នា ដូច ក្រាមសាប់ផា នៅតំបន់ជាយក្រុង ។ ដោយមិនគាំទ្រនូវគុណវិបត្តិទាំងនេះ ប្រជាជនតំបន់ជាយក្រុងជាច្រើន បានបង្កើត ម៉ូហាឡា សាមីទីស ឬ វៃតសាប់ផាដោយមានការជួយសម្រួលយ៉ាងសកម្មពី PRIA និងដៃគូ ។ អ្នកដឹកនាំពលរដ្ឋក្រោយពីបានហ្វឹកហាត់ និងបំពាក់នូវព័ត៌មានហើយ បានចាប់ផ្តើមប្រមូលផ្តុំ វៃតសាប់ផា ។ ពួកគេរួមគ្នាកំណត់ពីអាទិភាពអភិវឌ្ឍន៍ក្នុងតំបន់ និងធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាចាត់តាំង ដើម្បីរួមបញ្ចូលអាទិភាពទាំងនេះ ក្នុងផែនការ និង កម្មវិធីរបស់អាជ្ញាធរតំបន់ ។ សមាជិកក្រុមប្រឹក្សាចាត់តាំងក៏បានរកឃើញនូវវេទិកាប្រជាពលរដ្ឋថ្មីនៅក្នុងទម្រង់នៃ វៃតសាប់ផា ឬ មោហល្លៈ សាមីទីស ដើម្បីប្រមូលយកការគាំទ្រនយោបាយសម្រាប់ការងារអភិវឌ្ឍន៍ក្នុង វៃត របស់ពួកគេ។

(៣) ***ការចូលរួមក្នុងមន្ទីរខ្មែរដើម្បីទទួលបានសេវាកម្ម :*** ទោះបីជាធ្វើឱ្យ បញ្ចយ័ត្ន និងអាជ្ញាធរតំបន់ទទួលខុសត្រូវតាមច្បាប់ក្នុងការផ្តល់នូវសេវាកម្មចាំបាច់ដល់ប្រជាជនក៏ដោយ ក៏មន្ទីរខ្មែរតាមផ្នែក ដូចជាទឹកស្អាត, សុខភាព, ការអប់រំ នៅតែជាអ្នកផ្តល់សេវាដ៏សំខាន់ ។ ពួកគេក៏នៅតែមានទំនួលខុសត្រូវ

យ៉ាងសំខាន់ចំពោះស្ថាប័នគ្រប់គ្រងចាត់តាំងក្នុងតំបន់ និង ប្រជាជន ។ វាគ្មានជម្រើសដទៃទៀត សម្រាប់ប្រជាពលរដ្ឋទេ ក្រៅពីចូលរួមជាមួយមន្ទីរផ្តល់សេវាកម្មតាមផ្នែកនេះ ដើម្បីទាមទារសេវាដែលពួកគេត្រូវការសម្រាប់ជីវិតប្រចាំថ្ងៃ ។ មានឱកាសជាច្រើន ដែលអ្នកដឹកនាំពលរដ្ឋរួមគ្នាសហការជាមួយអ្នកតំណាងរាស្ត្រចាត់តាំង ដើម្បីទាមទារសេវាកម្មចាំបាច់ពីមន្ទីរទាំងនេះ ។ បញ្ហាដែលគេជួបប្រទះ មានតាំងពីទឹកស្អាតរហូតដល់ការបំពេញមុខងារ នៃបឋមសិក្សា, ការចែកចាយ របស់មជ្ឈមណ្ឌល អង់ហ្គុនវាឌីក្នុងស្រុកភូមិ, រហូតដល់ផ្លូវថ្នល់ជាដើម ។ ការទំនាក់ទំនងដ៏ច្រើនទាំងនេះមិនមែនតែងតែទទួលជោគជ័យក្នុងការចែកចាយសេវាទេ ដោយសារតែភាពមិនស្មើគ្នានៃទំនាក់ទំនងអំណាច និងអាកប្បកិរិយា មិនទទួលខុសត្រូវ និងព្រងើយកន្តើយនៃមន្ត្រីរដ្ឋ ។ ទោះជាយ៉ាងណាក៏ដោយ ការចូលរួមនេះចាប់ផ្តើមក្នុងទំហំមធ្យម ក្នុងការប្រើប្រាស់ និងបញ្ជាក់សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ពិសេសអ្នកក្រីក្រ និងប្រជាជនតូចតាចគ្មានអំណាច ។

(៤) ***ការចូលរួមជាមួយស្ថាប័នគ្រប់គ្រងដើម្បីដោះស្រាយបញ្ហាអយុត្តិធមិសង្គម និងការរើសអើងក្នុងសង្គម :*** បញ្ហាពាក់ព័ន្ធនឹងអយុត្តិធមិ និង ការរើសអើងមិនមែនជាបញ្ហាថ្មីក្នុងសង្គមទេ ប៉ុន្តែស្ថានភាពប្រែក្លាយកាន់តែធ្ងន់ធ្ងរនៅពេលដែលស្ថាប័នគ្រប់គ្រង ក្លាយជាឧបករណ៏សម្រាប់និរន្តភាពរបស់ពួកគេ ។ ក្នុងស្ថានការណ៏ជាច្រើន ស្ត្រី ដាលីត និង កុលសម្ព័ន្ធបានទទួលរងភាពឃោរឃៅពីអ្នកមានអំណាច ។ ក្នុងកាលៈទេសៈជាច្រើន អ្នកដឹកនាំប្រជាពលរដ្ឋពីក្រុមស្ត្រី ដាលីត និង កុលសម្ព័ន្ធ បន្ទាប់ពីជ្រួតជ្រាបមកក្រោយពីពេលបង្ខឹកបង្ហាត់, ការប្រឈមមុខ និងការនៅជាសមូហភាព បានបដិសេធមិនទទួលយកការគាបសង្កត់បង្ក្រាប់បញ្ហានេះទេ ។ ពួកគេបានប្រមូលផ្តុំគ្នា ហើយបង្ហាញនូវការប្រឆាំងចំពោះការរើសអើងក៏ដូចជាប្រឆាំងនឹងភាពអសកម្មរបស់អាជ្ញាធរសាធារណៈ ។ បញ្ហាអំពើហិង្សាក្នុងគ្រួសារត្រូវបាននាំទៅកាន់អាជ្ញាធរជាន់ខ្ពស់ដោយក្រុមស្ត្រីនៅតំបន់ជាច្រើន ។ បញ្ហាសិទ្ធិដីធ្លីរបស់ពួកដាលីតត្រូវបានដោះស្រាយតាមរយៈអង្គការផ្ទាល់របស់ពួកគេ ។

(៥) ***ការចូលរួមក្នុងការបោះឆ្នោតជ្រើសតាំង បញ្ចាយ័ត្សនិងអាជ្ញាធរក្នុងតំបន់ :*** PRIA និងដៃគូនៅរដ្ឋជាច្រើនបានបើកយុទ្ធនាការដ៏ធំមុនពេលបោះឆ្នោតជ្រើសរើសស្ថាប័ន បញ្ចយទ្ទី រ៉ាច និង អាជ្ញាធរតំបន់ ។ គោលបំណងនៃយុទ្ធនាការទាំងនេះ គឺដើម្បីអប់រំប្រជាពលរដ្ឋ និងអ្នកឈរឈ្មោះសម្រាប់តំណែងគ្រប់គ្រងតំបន់ឱ្យដឹងពីដំណើរការបោះឆ្នោតដោយសេរី និង យុត្តិធមិ ។ ក្រុមប្រជាពលរដ្ឋ និងអ្នកដឹកនាំដែលហ្វឹកហាត់តាមរយៈអន្តរាគមន៏នេះ បានចូលរួមយ៉ាងច្រើនក្នុងយុទ្ធនាការការយល់ដឹងរបស់អ្នកបោះឆ្នោតមុនពេលបោះឆ្នោតនេះ ទាំងក្នុងក្រុង និង ជនបទ ។ ពួកគេចូលរួមក្នុងបញ្ជីរាយឈ្មោះអ្នក

បោះឆ្នោត, ការរួមចំណែកក្នុងសម្ភារព័ត៌មាន, ការរៀបចំ "កាឡា ចាតហាល" និង ក្នុងយុទ្ធនាការអប់រំផ្ទាល់ ។ អ្នកដឹកនាំពលរដ្ឋមួយចំនួនបានគាំទ្រអ្នកដឹកនាំពលរដ្ឋដែលល្អគួរឱ្យទុកចិត្តឱ្យចូលរួមឈរឈ្មោះបោះឆ្នោត ឬក៏ពួកគេឈរឈ្មោះបោះឆ្នោតដោយខ្លួនឯង ។ យុទ្ធនាការទាំងនេះ គឺជាទីលានសិក្សាដ៏ល្អឥតខ្ចោះ សម្រាប់អ្នកដឹកនាំ ដើម្បីចូលរួមក្នុងដំណើរការនយោបាយក្នុងតំបន់ និង ដើម្បីទទួលបានការមើលឃើញនៅក្នុងសហគមន៏ ។

និន្នាការបច្ចុប្បន្នក្នុងឆាកនយោបាយសង្គម ត្រូវបានកំណត់លក្ខណៈដោយកម្រិតវិមជ្ឈការក្នុងតំបន់ និងយន្តការ សម្រាប់ការចូលរួមនយោបាយនៃជនគ្មានអំណាច និង ជនក្រីក្របច្ចុប្បន្ននេះ បានផ្តល់នូវបរិយាកាស ដើម្បីជំរុញការដឹកនាំប្រជាពលរដ្ឋ និងសមាគមប្រជាជន ។ ភាគច្រើននៅមិនទាន់មានការលូកលាន់ ពីស្ថាប័នគ្រប់គ្រង និង សង្គមស៊ីវិលនៅឡើយ ។ មានដើមទុនស្តួចស្តើងណាស់ ក្នុងទម្រង់ជាអន្តរាគមន៏អប់រំ និង ប្រមូលផ្តុំជាសម្ព័ន្ធដែលបានផ្តល់ឱ្យ ដើម្បីពង្រឹង និង ជំរុញការចាប់ផ្តើមការដឹកនាំទាំងនេះ ។ អន្តរាគមន៏របស់ PRIA និងដៃគូអំពីការពង្រឹងភាពជាអ្នកដឹកនាំពលរដ្ឋបានបង្ហាញថាជាករណីលើកលែងក្នុងន័យនេះ ។

ជាទូទៅ ភាគច្រើននៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៏ដោយរដ្ឋាភិបាល, ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលជាអន្តរការី ជាទ្វេភាគី ឬ ជាពហុភាគី បានបណ្តាលឱ្យមានការបង្កើតឡើងជាក្រុមសហគមន៏ ឬសមាគមដើម្បីធានាឱ្យមានការទទួលខុសត្រូវចំពោះការចែកចាយនូវកម្មវិធីជាក់លាក់ ។ ដូច្នេះក្រុមអ្នកប្រើប្រាស់ ថ្នាក់សហគមន៏ បានបង្កើតអ្វីដែលភាគច្រើនគេយល់ថា ជាយាននៃការបញ្ជូនសេវា និង ការចែកចាយ ។ ទោះជាគំនិតផ្តើមទាំងនេះ បានបង្កើត "មូលធនសង្គម" ច្រើនគួរសមក្នុងកម្រិតសហគមន៏ក៏ដោយ ដំណើរការនៃសតិសម្បជញ្ញៈ-- រង្វាស់នៃសកម្មភាពស្ម័គ្រចិត្តក្នុងទសវត្សរ៍ ៧០ -- មិនទាន់បានដោះស្រាយរួចរាល់នៅឡើយតាមរយៈការបង្កើតសហគមន៏នេះ ។ អន្តរាគមន៏ជំរុញការដឹកនាំពលរដ្ឋ បានជួយនាំយកមកវិញនូវដំណើរការសម្បជញ្ញៈស្មារតីក្រុម និង បុគ្គលមួយចំនួនធំតាមរយៈការឆ្លុះបញ្ចាំងមើលជារួមទៅលើការពិត និង ចំណាត់វិធានការបានសមស្រប ។

មកដល់សព្វថ្ងៃ ទស្សនៈស្តីអំពីសិទ្ធិបុគ្គលជាទូទៅបានដឹកនាំអន្តរាគមន៏កសាងសមត្ថភាព ។ ទោះបីជាសំខាន់យ៉ាងនេះក្តី វានៅមិនទាន់គ្រប់ល្មមដើម្បីជំរុញឱ្យប្រជាជនហ៊ាននិយាយអះអាងបញ្ជាក់ និង ទាក់ទងជាមួយនឹងទីភ្នាក់ងារអភិវឌ្ឍន៏កណ្តាលដទៃ មានដូចជាអង្គការសង្គមស៊ីវិលជាអន្តរការី និង ស្ថាប័នរដ្ឋ ។ ទស្សនៈនៃសមូហភាព និង ការចូលរួមរបស់ប្រជាជនក្នុងសកម្មភាពរួម មិនទាន់បានដោះស្រាយក្នុងលក្ខណៈជាប្រព័ន្ធនៅឡើយ ។ ភាពដឹកនាំខ្លាំងក្លានៅថ្នាក់ទាប ដែលជំរុញតាមរយៈអន្តរាគមន៏នេះ បានរីកចម្រើនយ៉ាងខ្លាំង

នាំទៅរកទំនាក់ទំនងដ៏មានប្រសិទ្ធភាពជាមួយស្ថាប័នដទៃ, ទទួលព័ត៌មាន និង ធនធានដទៃទៀតពីរដ្ឋាភិបាល, អង្គភាពតាមមូលដ្ឋាន, អង្គការសង្គមស៊ីវិល, និង ស្ថាប័នទីផ្សារ ។

តុល្យភាពដ៏សំខាន់រវាងទស្សនៈអភិវឌ្ឍន៍ស្តីអំពីភាពជាពលរដ្ឋ និង អភិបាលកិច្ច និង ការបណ្តុះបណ្តាល " ជំនាញការខាងសង្គម " (ឧ. ការប្រាស្រ័យទាក់ទងគ្នា, ការប្រមូលផ្តុំ, ការគ្រប់គ្រងសមូហភាពជាដើម) បានក្លាយជាមូលដ្ឋាននៃការរចនា និង បំប៉នការកសាងសមត្ថភាព ដែលនឹងជួយគាំទ្រដល់អ្នកដឹកនាំពលរដ្ឋ និង សមូហភាពទាំងនេះ ។ វិធីសាស្រ្តនេះផ្តល់ភាគលាភគួរឱ្យចាប់អារម្មណ៍ ដែលជាភស្តុតាងនៃលទ្ធផលចម្បង ទទួលបានតាមរយៈអន្តរាគមន៍នេះ ។

អន្តរាគមន៍កសាងសមត្ថភាពជាច្រើនរួមមាន អន្តរាគមន៍អប់រំជារចនាសម្ព័ន្ធ ដូចជាការបង្ហឹកបង្ហាត់, កម្មវិធីអប់រំណែនាំ, សន្និសីទ, ការគាំទ្រយ៉ាងជិតស្និទ្ធជាទៀងទាត់, ទស្សនកិច្ចខាងក្រៅ, និង ការបង្កើតបណ្តាញ ត្រូវបានផ្តល់ឱ្យដើម្បីរីកលូតលាស់, អភិវឌ្ឍន៍ និង ពង្រឹងការដឹកនាំប្រជាជន ពិតជាមានសារៈប្រយោជន៍ណាស់។ វិធីសាស្រ្តពហុមាគ៌ាដើម្បីកសាងសមត្ថភាព មានប្រសិទ្ធភាពជាងវិធីសាស្រ្តឯកមាគ៌ា ដូចជា ការមានតែការ បង្ហឹកបង្ហាត់តែមួយមុខ ឬ មានតែយុទ្ធនាការ ។ យ៉ាងណាមិញ ការខិតខំប្រឹងប្រែងគឺ ដើម្បីធ្វើឱ្យវិធីសាស្រ្ត ទាំងអស់ សក្តិសមសម្រាប់ការសិក្សានៃស្ត្រី និង បុរសមួយភាគធំដែលជាជនពាក់កណ្តាលអក្ខរកម្ម ឬ អនក្ខរកម្ម។